និយ័តករបរធនបាលកិច្ច
Trust Regulator
គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia
លេខ៧៣ ចេញផ្សាយថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣
No. 73 Released on Sep 11, 2023
អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# លិខិតបរធនបាលកិច្ចដែលស្របតាមច្បាប់

## Trust Deed Complying with the Law




https://www.bing.com/images/search?view=detailV2&ccid=K%2fiKAOpi&id=E9619259E69A9CD0F7907779CE0828036CD5EEB

### ១. ប្រតិបត្តិការបរធនបាលកិច្ច

ប្រតិបត្តិការបរធនបាលកិច្ចជាចំណងគតិយុត្តរវាងបុគ្គលម្នាក់ដែលជាម្ចាស់ទ្រព្យសម្បត្តិ ហៅថាបរធនបាលទាយក បានយកទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបុគ្គលដទៃទៀត (រូបវន្តបុគ្គល ឬនីតិបុគ្គល) ហៅថាបរធនបាល ដើម្បីគ្រប់គ្រង ចាត់ចែង និងថែរក្សាជំនួស តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន សម្រាប់ជាប្រយោជន៍ដល់អ្នកដទៃ ហៅថាអត្ថគាហកៈ។

### ២. អ្វីទៅជាលិខិតបរធនបាលកិច្ច?

យោងតាមច្បាប់ស្តីពីបរធនបាលកិច្ច លិខិតបរធនបាលកិច្ចសំដៅដល់÷ **(ក)** លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពី ការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដោយមានការបញ្ជាក់ពីសាការី ឬមេធាវី ឬឃុំសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន **(ខ)** មតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។ ក្នុងន័យនេះ លិខិតបរធនបាលកិច្ចអាចមានន័យថា ជាឯកសារផ្លូវច្បាប់ដែលបង្កើតបរធនបាលកិច្ចដោយម្ចាស់ទ្រព្យ(បរធនបាលទាយក) ផ្តល់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល(បរធនបាល) នូវសិទ្ធិក្នុងការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិ ឬមូលនិធិ សម្រាប់ជាប្រយោជន៍ដល់នរណាម្នាក់ផ្សេងទៀត(អត្ថគាហកៈ) ដោយភ្ជាប់នូវលក្ខខណ្ឌនិងយន្តការនៃការអនុវត្តយ៉ាងច្បាស់លាស់។

### ៣. ទម្រង់លិខិតបរធនបាលកិច្ច

លិខិតបរធនបាលកិច្ចត្រូវរៀបចំឡើងដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដោយត្រូវកំណត់នូវសិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាលទាយក, សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់បរធនបាល, និងសិទ្ធិរបស់អត្ថគាហកៈ។ លិខិតបរធនបាលកិច្ចត្រូវមាននិទ្ទេសអប្បបរមាដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច។ បន្ថែមលើនេះ គូភាគីក៏អាចកំណត់ និងបន្ថែមលក្ខខណ្ឌផ្សេងៗតាមឆន្ទៈរបស់ខ្លួនផងដែរ លើកលែងតែ ខចែង ដូចជា÷ ឱ្យមានការរួចផុតការទទួលខុសត្រូវរបស់បរធនបាលលើការរំលោភបំពានលើបរធនបាលកិច្ច, ការយកទ្រព្យសម្បត្តិបរធនបាលកិច្ចទៅទូទាត់សំណង ឬចំណាយរបស់បរធនបាល, ការយកទ្រព្យសម្បត្តិបរធនបាលកិច្ចទៅទូទាត់ក្នុងការជម្រះបញ្ជីឬក្ស័យធន និងខចែងដែលមានលក្ខណៈផ្ទុយទៅនឹងសណ្តាប់ធ្នាប់និងផលប្រយោជន៍សាធារណៈ ដែលមិនចាត់ទុកថាមាន សុពលភាព និងមិនអនុញ្ញាតឱ្យចែងក្នុងលិខិតបរធនបាលកិច្ច។

### ៤. លក្ខខណ្ឌសុពលភាពនៃលិខិតបរធនបាលកិច្ច

លិខិតបរធនបាលកិច្ចដែលត្រឹមត្រូវនិងមានសុពលភាព**ត្រូវចុះបញ្ជី និងតម្កល់នៅ ន.ប.ធ.។**

### ៥. ការចុះបញ្ជីលិខិតបរធនបាលកិច្ច

ការធ្វើប្រតិបត្តិការបរធនបាលកិច្ចដោយមិនចុះបញ្ជី គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវទទួលរងការផាកពិន័យ និងផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៤៣ នៃច្បាប់ស្តីពីបរធនបាលកិច្ច។

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia www.trustregulator.gov.kh (855) 23 237 888
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

**1. Trust**

Trust is a legal relationship between 3 parties which includes: the Trustor who is a property owner, giving his/her property to another person (natural person or legal entity) called, Trustee to manage, administer and safeguard-keep on his/her behalf in accordance with the conditions determined by the Trust Deed or applicable provisions for the benefit of other persons, called Beneficiary.

**2. What is Trust Deed?**

According to the Law on Trust, Trust Deed refers to ÷ (a). A Legal Document which specifies the establishment, management, administration and termination of the Trust, with the verification/authentication by a notary, a lawyer, or the commune/Sangkat; or by other persons as stated in the applicable provisions. (b). A Will and Testament formed in accordance with the provisions of the Succession of the Civil Code. In this respect, Trust Deed can be defined as a legal document which creates a Trust, by the property owner (Trustor), giving a natural person or legal person (Trustee) the right to manage, administer the property or funds for the benefit of someone else (beneficiary), with explicit conditions and mechanisms for execution attached.

**3. Trust Deed Form**

Trust Deed shall be formed complying with the applicable laws and regulations, by determining the rights and obligations of the Trustor, rights, obligations, and responsibilities of the Trustee and rights of the Beneficiary. Trust Deed shall have the minimum requirements as stated in Article 6 of the Sub-Decree on Trust Registration. In addition, the parties may determine and add-on other conditions at their own discretion, except as follows: exempting the Trustee from liability for breach of Trust, disposal of Trust property for payment of compensation or Trustee's expenses, disposal of Trust Property in liquidation or bankruptcy, and provisions that are contrary to the public order and public interest; these are NOT considered valid and acceptable in Trust Deed.

**4. Validity Conditions of Trust Deed**

Trust Deed which is legal and valid shall be formed in accordance with the Trust Law and other applicable regulations and **shall be registered and held the TR.**

**5. Trust Registration**

Unregistered Trust Operation constitutes a criminal breach, with fines and punishment imposed as stated in Article 43 of the law on Trust.

**អត្ថបទ÷ លោក រិន វីរៈ | Article: Mr. Rin Vireak**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច
- អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- ប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.